**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ៣៣៦ ក.ប/ស.ជ.ណ.ប.ស.ស

## សេចក្តីជូនដំណឹង
## ស្តីពី
## ការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

**យោង៖** -មាត្រា២ នៃច្បាប់ស្តីពីការងារ
-ប្រកាសអន្តរក្រសួងលេខ ៤០៤ ក.ប/ ប្រក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជ្រាបថា ដើម្បីអនុវត្តអនុសាសន៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានស្នើឲ្យនិយោជក ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលកំពុងប្រើប្រាស់កម្មករនិយោជិតម្នាក់ ឬច្រើននាក់ ត្រូវមានកាតព្វកិច្ចចុះបញ្ជីសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានរបបសន្តិសុខសង្គម ដោយឡែកសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធនឹងទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុងនិងក្រៅប្រព័ន្ធ។

អាស្រ័យហេតុនេះ ក្រសួង សូមអញ្ជើញ និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន ដែលមិនទាន់បានចុះបញ្ជីនៅ ប.ស.ស សូមប្រញាប់មកចុះបញ្ជីឲ្យបានមុនថ្ងៃអាទិត្យ ១៤ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ គ.ស ២០១៧ នៅអគារ ប.ស.ស (ស្នាក់ការកណ្តាល) ក្នុងបរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតាមសាខា ប.ស.ស ខេត្ត/ខណ្ឌ។

ក្នុងករណីខកខាន មិនបានចុះបញ្ជីតាមការកំណត់ខាងលើ និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន ត្រូវទទួលខុសត្រូវនៅចំពោះមុខច្បាប់ ពិសេសត្រូវផ្តល់អត្ថប្រយោជន៍ដល់ បុគ្គលិក កម្មករនិយោជិត ដែលខ្លួនកំពុងប្រើប្រាស់(របបសន្តិសុខសង្គម សេវាមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន)។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថានទាំងអស់ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ គ.ស ២០១៧
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩